ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះសីហនុ
លេខ: ៤៥៧/២៣ សរណ

ថ្ងៃ សុក្រ ១២រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តព្រះសីហនុ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដេញថ្លៃតាស៊ីចំណតយានជំនិះ ក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

រដ្ឋបាលខេត្តព្រះសីហនុ សូមជម្រាបជូនដំណឹងដល់សាធារណជនអោយបានជ្រាបថា ៖ ដើម្បីប្រមូលចំណូលពីចំណតយានជំនិះក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចូលក្នុងថវិការដ្ឋ រដ្ឋបាលខេត្តព្រះសីហនុ នឹងរៀបចំធ្វើការដេញថ្លៃចំណតយានជំនិះសម្រាប់ធ្វើអាជីវកម្មឆ្នាំ២០២៤ នៅតាមទីតាំងដូចខាងក្រោម ៖

- ចំណតយានជំនិះមុខផ្សារលើក្រុងព្រះសីហនុ ស្ថិតនៅភូមិ១ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- ចំណតយានជំនិះមហោស្របចាស់ ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- ចំណតយានជំនិះផ្លូវអូរឈើទាល ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

កាលបរិច្ឆេទនៃការដេញថ្លៃ៖នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ០៧៖៣០នាទីព្រឹក
ទីកន្លែង៖មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះសីហនុ

រដ្ឋបាលខេត្តព្រះសីហនុ បានរៀបចំឯកសារសម្រាប់ដាក់ពាក្យចូលរួមដេញថ្លៃ និងមានដាក់លក់នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ រៀងរាល់ម៉ោងធ្វើការ ឬទំនាក់ទំនងតាមលេខទូរស័ព្ទ៖ ០១៦ ៨៩៨ ៣៥០។

លក្ខខណ្ឌនៃការចូលរួមដេញថ្លៃ មានដូចខាងក្រោម៖

**I- ការដាក់ដេញថ្លៃតាស៊ីចំណតយានជំនិះ**

- នីតិបុគ្គល ឬរូបវន្តបុគ្គល ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅមានសិទ្ធិចូលរួមដេញថ្លៃ ដោយត្រូវបំពេញសំណុំបែបបទសុំចូលរួមដេញថ្លៃ តាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ។ដោយឡែកមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សិស្ស និស្សិត គឺពុំមានសិទ្ធិចូលរួមដេញថ្លៃបានទេ។
- តម្លៃមូលដ្ឋានតាស៊ីចំណតយានជំនិះក្នុងក្រុងព្រះសីហនុគឺ ២៥០.០០០.០០០៛ (ពីររយហាសិបលានរៀលគត់) សម្រាប់រយៈពេល មួយឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។
- ការដេញថ្លៃត្រូវអនុវត្តតាមរូបភាពដេញថ្លៃឡើង ដោយដាក់ក្នុងស្រោមសំបុត្រជា ៣លើក។/.

- កាលបរិច្ឆេទនៃការទទួលពាក្យ ចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ និងឈប់ទទួលពាក្យនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៧ និង០០ នាទីល្ងាច។

**II-លក្ខខណ្ឌអ្នកចូលរួមដេញថ្លៃ**

ពាក្យសុំចូលរួមដេញថ្លៃ ត្រូវភ្ជាប់មកជាមួយនូវ៖

- ជីវប្រវត្តិសង្ខេបមានបិទរូបថតទំហំ ៤x៦ ចំនួន០២ ច្បាប់
- អត្តសញ្ញាណបណ្ណថតចម្លងដោយមានការបញ្ជាក់ទទួលស្គាល់ពីមន្ត្រីមានសមត្ថកិច្ចចំនួន០២ ច្បាប់
- បង្កាន់ដៃប្រាក់កក់បណ្តោះអាសន្ន ចំនួន ២០% នៃតម្លៃមូលដ្ឋាន០២ច្បាប់
- ឯកសារបញ្ជាក់ទ្រព្យសម្បត្តិ ឬអចលនវត្ថុធានាបណ្តោះអាសន្ន៥០% នៃតម្លៃមូលដ្ឋាន ចំនួន០២ ច្បាប់
- កិច្ចសន្យាស្តីពីការប្រគល់ប្រាក់ធានាបណ្តោះអាសន្ន និងពិន័យជូនរដ្ឋ ចំនួន០២ ច្បាប់
- កិច្ចសន្យាស្តីពីការប្រគល់ប្រាក់ធានាស្ថាពរជូនរដ្ឋ ចំនួន០២ ច្បាប់។

**សម្រាប់ព័ត៌មានបន្ថែម**

សូមទំនាក់ទំនងផ្ទាល់ មកការិយាល័យទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះសីហនុ រៀងរាល់ម៉ោងធ្វើការ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាប និងអញ្ជើញមកដាក់ពាក្យដេញថ្លៃអោយបានច្រើនកុះករ។

**អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ**

**គួច_ចំរើន**

ចម្លងជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីគោរពជូនជ្រាប"
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- រដ្ឋបាលក្រុងព្រះសីហនុ
- មន្ទីរព័ត៌មាន
- គ្រប់បណ្តាញសារព័ត៌មាន
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ